## ព្រះរាជាណាចក្រកម្ពុជា

### ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ

## សូមគោរពជូន

## សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សម្តេចក្រឡាហោម** ជាទីគោរពរាប់អានដ៏ខ្ពង់ខ្ពស់បំផុត !

ជាបឋម តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ព្រមទាំង នាយទាហាន នាយទាហានរង និង ពលទាហាន នៃកងយោធពលខេមរភូមិន្ទទាំងអស់ និងក្នុងនាមខ្ញុំ និងភរិយាខ្ញុំ សូមសម្តែងនូវមនោសញ្ចេតនាអបអរសាទរដ៏ក្លៀវក្លាបំផុតចំពោះ **សម្តេច** ដែលត្រូវបាន **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** ទ្រង់សព្វព្រះរាជហឫទ័យ ប្រោសព្រះរាជទានគោរមងារជា **សម្តេចក្រឡាហោម ស ខេង** តាមព្រះរាជក្រឹត្យ នស/រកត/០៦១៥/៦៣៤ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៥ ថ្មីៗនេះ។

ព្រះរាជគោរមងារ **សម្តេចក្រឡាហោម** ដែល **ព្រះករុណា ជាអម្ចាស់ជីវិតលើត្បូង** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុតទ្រង់សព្វព្រះរាជហឫទ័យប្រោសព្រះរាជទានជូន **សម្តេច** នាឱកាសនេះ ពិតជាស័ក្តិសមនឹងគុណបំណាច់ដ៏ឧត្តុង្គឧត្តមរបស់ **សម្តេច** ដែលហ៊ានធ្វើពលិកម្មសព្វបែបយ៉ាងដើម្បីបម្រើឧត្តមប្រយោជន៍ **ជាតិ សាសនា ព្រះមហាក្សត្រ** ក្នុងបំណងសុខសន្តិភាពទាំងផ្លូវកាយ ទាំងផ្លូវចិត្តជានិច្ចនិរន្តរ៍តរៀងទៅ។

ជាថ្មីម្តងទៀត យើងខ្ញុំសូមប្រសិទ្ធិពរជ័យមហាប្រសើរ សូម **សម្តេច** និង **លោកជំទាវ** ព្រមទាំង ក្រុមគ្រួសារ បានសមប្រកបដោយព្រះពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេច** ទទួលនូវការគោរពស្រឡាញ់ ដ៏ជ្រាលជ្រៅបំផុតអំពីខ្ញុំ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៥

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**នាយឧត្តមសេនីយ៍ ផ្កាយមាស៤ ទៀ បាញ់**